# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

នាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាល
មក ដល់ ម៉ោង: ១១ម៉ោង៣
ថ្ងៃទី ០៦ ខែ ០៩ ឆ្នាំ ២០១៧
លេខ: ៩៤១.ន.ប.ប.

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៧៦១ អយក. សាជ៧

# សេចក្តីជូនដំណឹង
## ស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតក្រោមគម្រោងអាហារូបករណ៍របស់ប្រទេសជប៉ុនសម្រាប់ ការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០១៨

**យោង** : សំណើសុំធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការជ្រើសរើសនិស្សិតអាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុនក្រោមគម្រោង JDS សម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ របស់ការិយាល័យ JICE-JDS នៅភ្នំពេញ ។

## ក្រសួងអប់រំ យុវជន និងកីឡា

សូមជូនដំណឹងដល់មន្ត្រីរាជការទាំងពីរភេទក្នុងស្ថាប័នរដ្ឋថា កម្មវិធីអាហារូបករណ៍ JDS ក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុនសម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា នឹងទទួលបណ្តុះបណ្តាលនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ **(Master's Degree)** រយៈពេល**២**ឆ្នាំ ចំនួន **២៤**នាក់ និងថ្នាក់បណ្ឌិត **(Ph. D Degree)** រយៈពេល **០៣**ឆ្នាំ ចំនួន **០២**នាក់ នៅប្រទេសជប៉ុន ក្នុងឆ្នាំ២០១៨ ។

មធ្យោបាយធ្វើដំណើរទៅមក កម្ពុជា-ជប៉ុន-កម្ពុជា ថ្លៃសិក្សា ប្រាក់អាហារូបករណ៍ ជាបន្ទុករបស់រដ្ឋាភិបាលជប៉ុន។

### I - <u>លក្ខខណ្ឌនៃការជ្រើសរើស</u>

**១. ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**បេក្ខជនទាំងពីរភេទត្រូវ:**

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្របរិញ្ញាបត្រ (Bachelor's Degree)
- មានអាយុចន្លោះពី **២២-៣៩ឆ្នាំ** គិតដល់ថ្ងៃទី**០១** ខែមេសា ឆ្នាំ**២០១៨**
- មានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់ ព្រោះការសិក្សាយកភាសាអង់គ្លេសជាយាន
- មានបទពិសោធន៍ការងារយ៉ាងតិច **០២**ឆ្នាំ ជាបុគ្គលិករដ្ឋដែលធ្វើការពេញម៉ោងតាមស្ថាប័នពាក់ព័ន្ធ (ចំពោះបុគ្គលិកជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាតទេ) ។
- មានសុខភាពល្អបរិបូណ៌ទាំងកាយសម្បទា និងសតិបញ្ញា


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh